ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែធ្នូ ឆ្នាំ២០២២

នៅក្នុងខែធ្នូ ឆ្នាំ២០២២នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

## ១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១-សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា

#### ១.១.១-សកម្មភាពចូលរួមកិច្ចប្រជុំ

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០១លើក។

#### ១.១.២-បដិសណ្ឋារកិច្ចឡើវជាតិ-អន្តរជាតិ

-បានអនុញ្ញាតឱ្យឯកឧត្តម Christophe-André Frassa សមាជិកព្រឹទ្ធសភាបារាំង និងជាប្រធានគណៈកម្មការនយោបាយ (APF) ចូលជួបសម្តែងការគួរសម និងសវនាការ នៅវិមានព្រឹទ្ធសភា។

#### ១.១.៣-សកម្មភាពចុះមូលដ្ឋាន

-បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខមន្ត្រី អាជ្ញាធរ និងប្រជាពលរដ្ឋ នៅក្រុងកំពង់សោម ខេត្តព្រះសីហនុ។

#### ១.១.៤-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធឯកឧត្តម **ជាំង ជឺមិន** អតីតប្រធានាធិបតី នៃសាធារណរដ្ឋប្រជាមានិតចិន នៅស្ថានឯកអគ្គរដ្ឋទូតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

#### ១.១.៥-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន០៧ច្បាប់។

**១.២ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**១.២.១-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន ០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០១លើក។

**១.២.២-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការទូទាំងខេត្តកណ្តាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-បានអនុញ្ញាតឱ្យក្រុមការងារដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ទៅពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋចំនួន២៦០នាក់ ស្ថិតនៅក្នុងឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់។

**១.២.៣-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញជាអធិបតីក្នុងពិធីបើកវេទិកាស្តីពី " ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រី ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ " នៅខេត្តសៀមរាប

-អញ្ជើញជាគណៈអធិបតីក្នុងកម្មវិធីសិក្ខាសាលាស្តីពី " កម្ពុជា-ចិន "រួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងពិធីប្រគល់-ទទួលអំណោយឧបករណ៍តេស្តរហ័សពិនិត្យរកជំងឺកូវីដ-១៩ នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធឧបដ្ឋានសាលា រួមជាមួយសំណង់ផ្សេងៗ និងពិធីចម្រើនព្រះជន្មព្រះចៅអធិការវត្តព្រែកជ្រៃ ស្ថិតនៅភូមិបារគូ សង្កាត់ជង្កោ ខណ្ឌជង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍លើកទី៤៤ នៃទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា (០២ធ្នូ ១៩៧៨-០២ធ្នូ ២០២២) នៅសាលសន្និសីទចតុមុខរាជធានីភ្នំពេញ

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសពមហាឧបាសកពុទ្ធសាសនូបត្ថម្ភក៍ **អំ សុខ** ញោមបង្កើតរបស់សម្តេចព្រះពោធិវ័ង្សកិត្តិបណ្ឌិត **អំ លីមហេង** ដែលបានទទួលមរណភាពក្នុងជន្មាយុ៨៩ឆ្នាំ ដោយជរាពាធ

-បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធកុដិមួយខ្នង រួមនឹងសមិទ្ធផលនានា នៅ

វត្តតាំងក្រសាំងខាងជើង ស្ថិតក្នុងសង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

-បានអញ្ជើញសួរសុខទុក្ខឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** អនុប្រធានទី១ ព្រឹទ្ធសភា នៅគេហដ្ឋាន រាជធានីភ្នំពេញ។

**១.២.៤-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១២ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១២ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញព្រឹទ្ធសភា ពិនិត្យ និងសម្រេចលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៩ នីតិកាលទី៤ ចំនួន០១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** ប្រធានស្តីទីព្រឹទ្ធសភា ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១

២-សេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

៣-សេចក្តីព្រាងច្បាប់ ស្តីពីការអនុម័តយល់ព្រមលើ ៖

១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មអនុសញ្ញា ស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិដោយបន្ថែមមាត្រា៣ស្ទួន

២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក) នៃអនុសញ្ញាស្តីពីអាកាសចរណ៍ស៊ីវិលអន្តរជាតិ

៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញា ស្តីពីអាកាសចរណ៍អន្តរជាតិ។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួន

ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### **៤.១ មុខងារនីតិកម្ម**

-បានអញ្ជើញចូលរួមកិច្ចប្រជុំអន្តរគណៈកម្មការ ជាមួយតំណាងរាជរដ្ឋាភិបាលដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងឯកឧត្តមបណ្ឌិត **ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រីទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់

-បានអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាលើសេចក្តីព្រាងច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិសិទ្ធិមនុស្សកម្ពុជា ក្រោមអធិបតីភាព ឯកឧត្តម យ៉ង់ សែម ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមប្រជុំពិគ្រោះយោបល់ ស្តីពីការបង្កើតគណៈកម្មការពិសេស និងនីតិវិធីការងារ ដើម្បីរៀបចំសេចក្តីស្នើវិសោធនកម្មបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។

### **៤.២ មុខងារតាមដានការអនុវត្តច្បាប់**

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការប្រមូលព័ត៌មានការផ្សព្វផ្សាយច្បាប់ ព្រមទាំងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីការអនុវត្តច្បាប់អន្តោប្រវេសន៍ ច្បាប់ស្តីពីរបបសារព័ត៌មាន ច្បាប់ស្តីពីការងារ ការផ្សព្វផ្សាយព័ត៌មាន និងការអភិវឌ្ឍលើវិស័យនានារបស់ខេត្តមណ្ឌលគិរី ខេត្តរតនគិរី និងខេត្តស្ទឹងត្រែង

-បានអញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់អំពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ លទ្ធផលនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ វឌ្ឍនភាព និងបញ្ហាប្រឈមនានានៃការអភិវឌ្ឍមូលដ្ឋាន នៅខេត្តពោធិ៍សាត់ និងខេត្តបន្ទាយមានជ័យ។

### **៤.៣ មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៣ករណី កំពុងពិនិត្យសិក្សាចំនួន០៩ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងពីក្រសួងការពារជាតិ បានចំនួន០១ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងបានចំនួន០៧ករណី។

-បានអញ្ជើញចូលរួមក្នុងវេទិកាក្រោមប្រធានបទស្តីពី " ការពង្រឹងសមត្ថភាពដឹកនាំរបស់សមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ជាស្ត្រីក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ " និងសិក្ខាសាលាស្តីពី " កម្ពុជា-ចិន រួមជោគវាសនាប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ " និងពិធីប្រគល់-ទទួលអំណោយឧបករណ៍តេស្តរហ័សពិនិត្យរកជំងឺកូវីដ-១៩ ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា

-បានសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃបេសកកម្មមនុស្សធម៌ (AMH) នៃប្រទេសបារាំង-កម្ពុជារបស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា ចុះពិនិត្យ និងព្យាបាលជំងឺទូទៅឥតគិតថ្លៃជូនប្រជាពលរដ្ឋក្រីក្រ នៅក្នុងបរិវេណសាលាឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ

-បានអញ្ជើញនាំយកឱសថ និងសម្ភារវេជ្ជសាស្ត្រ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ ដែលបានពីមូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ជូនអាជ្ញាធរខេត្តពោធិ៍សាត់ នៅសាលាខេត្តពោធិ៍សាត់

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបើក និងពិធីបិទជាផ្លូវការកីឡាជាតិលើកទី៣ ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមពិធីបើកជាផ្លូវការពិធីបុណ្យសមុទ្រលើកទី៩ ជុំទី៣ ឆ្នាំ២០២២ ក្រោមប្រធានបទ "ឆ្នេរនៃសន្តិភាព ឆ្នេរនៃក្តីសង្ឃឹម" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញចូលរួមជាគណៈអធិបតីមិទ្ទីញអបអរសាទរខួបអនុស្សាវរីយ៍ លើកទី៤៤ ទិវាកំណើតរណសិរ្សសាមគ្គីអភិវឌ្ឍន៍មាតុភូមិកម្ពុជា ០២ធ្នូ ១៩៧៨ - ០២ធ្នូ ២០២២ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ ១០ ធ្នូ លើកទី៧៤ ក្រោមប្រធានបទ "ខួបលើកទី៧៥ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ជាម យៀប** អនុប្រធាន

ទី១ នៃរដ្ឋសភា នៅសាលសិក្ខាសាលាបណ្ណាល័យព្រឹទ្ធសភា

-បានអញ្ជើញចូលរួមពិធីគោរពវិញ្ញាណក្ខន្ធឯកឧត្តម **ជាំង ជឺមិន** អតីតប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា នៅស្ថានឯកអគ្គរដ្ឋទូតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា

-បានអញ្ជើញជាគណៈអធិបតីក្នុងពិធីសម្ពោធសមិទ្ធផល និងចូលរួមជាកិត្តិយសក្នុងពិធីផ្លូវការផ្សេងៗចំនួន១១២លើក

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំអាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខសណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ជាពិសេស ពិនិត្យដំណើរការចុះឈ្មោះបោះឆ្នោត នៅតាមមូលដ្ឋានរៀងៗខ្លួនក្នុងភូមិភាគទាំង៨ ចំនួន៧៥លើក។

## ៤.៤ កិច្ចសហប្រតិបត្តិការអន្តរជាតិ

ការងារសហប្រតិបត្តិការអន្តរជាតិរបស់ព្រឹទ្ធសភា ជាពិសេស ទំនាក់ទំនងក្នុងកម្រិតតំបន់ និងអន្តរជាតិ សមាជិក សមាជិកាព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម និងទទួលបានលទ្ធផលជាវិជ្ជមានដូចខាងក្រោម៖

-បានអញ្ជើញចូលរួមកិច្ចប្រជុំលើកទី១០ នៃសភាប្រើប្រាស់ភាសាបារាំង(APF) តំបន់អាស៊ី-ប៉ាស៊ីហ្វិក នៅទីក្រុងដាណាង ប្រទេសវៀតណាម

-បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូបេសកកម្មសុឆន្ទៈនៃសភាប្រើភាសាបារាំង (APF) ដឹកនាំដោយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈប្រតិភូមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា

-បានអនុញ្ញាតឱ្យឯកឧត្តម Zaheeruddin Babar Thaheem ឯកអគ្គរដ្ឋទូតវិសាមញ្ញ

និងពេញសមត្ថភាព នៃស្ថានទូតសាធារណរដ្ឋឥស្លាមប៉ាគីស្ថាន ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម

-បានអនុញ្ញាតឱ្យប្រធានសម្ព័ន្ធសភាកូរ៉េ ស្តីពីកុមារ ប្រជាជន និងបរិស្ថាន នៃសាធារណរដ្ឋកូរ៉េ ចូលជួបពិភាក្សាការងារ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបំពាក់គ្រឿងឥស្សរិយយស Odre de la Pleiade (Grade de Commandeur) ពីសភាប្រើប្រាស់ភាសាបារាំង ជូនឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ម៉ុម ជឹមហ៊ុយ** ប្រធានគណៈកម្មការទី៧ ដែលត្រូវបានបំពាក់ដោយឯកឧត្តម Christophe-André Frassa ប្រធានគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង(APF) នៅវិមានព្រឹទ្ធសភា

-គណៈប្រតិភូក្រុមមិត្តភាពសភាកម្ពុជាជាមួយរដ្ឋសភាវៀតណាម បានអញ្ជើញបំពេញទស្សនកិច្ចការងារ និងចូលរួមកិច្ចប្រជុំក្រុមមិត្តភាពនៃសភាប្រទេសទាំងពីរ នៅទីក្រុងដាណាង ខេត្តក្វាងណាម សាធារណរដ្ឋសង្គមនិយមវៀតណាម

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកា នៃបណ្តាប្រទេសជាសមាជិកអាយប៉ា និងប្រទេសអ្នកសង្កេតការណ៍ភ្ញៀវជាតិ និងអន្តរជាតិក្នុងឱកាសដែលព្រះរាជាណាចក្រកម្ពុជា ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំនៃមហាសន្និបាតអន្តរសភាអាស៊ានលើកទី៤៣ ASEAN Inter-Parliamentary Assembly (AIPA-43) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** អនុប្រធានទី២ ព្រឹទ្ធសភា នៅសណ្ឋាគារសុខារាជធានីភ្នំពេញ។

ថ្ងៃ *អង្គារ ១២ កើត* ខែ *បុស្ស* ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី *០៣* ខែ *មករា* ឆ្នាំ២០២៣

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**កិត្តិសង្គហបណ្ឌិត ទេព ងន**

<u>ចម្លងជូន</u>
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ